# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

**ភាគីដាក់ឯកសារ:** ក្រុមមេធាវីការពារក្តីលោក នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះតុលាការកំពូល

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី១៣ ខែសីហា ឆ្នាំ ២០១៩

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Aug-2019, 13:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ត.ក** សាធារណៈ/Public

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ**

**ហត្ថលេខា:**

---

# សំណើបន្ទាន់ដើម្បីតែងតាំងក្រុមមេធាវីការពារក្តី នួន ជា ឡើងវិញ

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា**
សុន អរុណ
លីវ សុវណ្ណា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
ឌី សុជាតា
Gaëlle BUCHET
Stephanie ERIAN
Khady BÂ

**ផ្ញើជូន៖**

**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence Ndepele Mwachande MUMBA
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Phillip RAPOZA
ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda J. HOLLIS (បម្រុង)

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ

**ក្រុមមេធាវីការពារក្តី ខៀវ សំផន**
គង់ សំអុន
Anta GUISSÉ

## ផ្នែកទី១. សេចក្តីផ្តើម

១. អនុលោមតាមវិធានផ្ទៃក្នុង មាត្រា៨៥ និង ១០៤ស្ទួន សហមេធាវីរបស់លោក នួន ជា (តទៅហៅថា "ក្រុមមេធាវីការពារ") ដាក់សំណើនេះដើម្បីស្នើសុំដីកាបង្គាប់បន្ទាន់មួយអោយមានការរក្សាទុកក្រុមការពារក្តីរបស់លោក នួន ជា (ក្នុងនោះរួមមានសមាជិកក្រុមទាំងអស់ដែលត្រូវបានរដ្ឋបាលរបស់អ.វ.ត.ក រំលាយចោលនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ ) រហូតដល់ពេលដែលអង្គជំនុំជម្រះតុលាការកំពូល (តទៅហៅថា "អង្គជំនុំជម្រះ") ធ្វើការសម្រេចរំសាយចោលក្រុមការពារក្តី (តទៅហៅថា "សំណើ")។

## ផ្នែកទី២. សាវតា

### I. បណ្តឹងសាទុក្ខរបស់ នួន ជា

២. ក្រោយពេលមានការចេញ សាលក្រម ដែលមានសំអាងហេតុពេញលេញក្នុងសំណុំរឿង០០២/០២ រួចមកនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៩[1] លោក នួន ជា បានជូនដំណឹងពីការប្តឹងសាទុក្ខចំពោះសាលក្រមនេះនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩។ ការជូនដំណឹងនេះបានលើកឡើងនូវមូលដ្ឋានប្តឹងសាទុក្ខសរុបចំនួន៣៥១ ក្នុងនោះមានមូលដ្ឋាននីមួយៗចំនួន៥៤៣ដាច់ដោយឡែកពីគ្នា ដែលអំណះអំណាងទាំងនេះអាចមានលទ្ធភាពច្រានចោលសាលក្រមអោយអស់សុពលភាពទាំងស្រុងតែម្តង។[2] បន្ទាប់ពីដាក់ការជូនដំណឹងនេះភ្លាម ក្រុមមេធាវីការពារបានចាប់ផ្តើមសរសេរសារណាអំពីបណ្តឹងសាទុក្ខរបស់លោក នួន ជា។

---

[1] E426 "សាលក្រមសំណុំរឿង០០២/០២", ១៦ វិច្ឆិកា ២០១៨។ [*sic* - ២៩ មេសា ២០១៩]

[2] E465/3/1 "សេចក្តីជូនដំណឹងរបស់ នួន ជា អំពីបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០២", ០១ កក្កដា ២០១៩

## II. សុខភាពរបស់លោក នួន ជា និងការទទួលមរណភាព

៣. លោក នួន ជា បានបញ្ជូនចូលទៅមន្ទីរពេទ្យ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៩។[3]

៤. ដើម្បីបង្ការ និងរៀបចំទុកមុនក្នុងករណីមានហេតុការណ៍ជាយថាហេតុណាមួយ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ លោក នួន ជា បានផ្ដល់លិខិតប្រគល់សិទ្ធិមកអោយក្រុមមេធាវីការពារ និងសមាជិកក្រុមគ្រួសាររបស់លោកមួយចំនួន ដើម្បីបន្តនីតិវិធីក្នុងនាមរូបគាត់ប្រសិនបើគាត់ទទួលមរណភាព។[4]

៥. នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៩ លោក នួន ជា បានទទួលមរណភាព។[5]

## III. សំណើមេធាវីការពារក្ដីអំពីផលប៉ះពាល់នៃមរណភាពរបស់ នួន ជា

៦. នៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ ក្រុមមេធាវីការពារបានដាក់សំណើមួយមានចំនួន២៥ទំព័រ ទៅអង្គជំនុំជម្រះដើម្បីសុំការបញ្ជាក់អំពីផលប៉ះពាល់នៃមរណភាពរបស់លោក នួន ជា ទៅលើនីតិវិធីបណ្ដឹងសាទុក្ខនៃសំណុំរឿង០០២/០២ មុនពេលចេញសាលដីកា (“សំណើបន្ទាន់របស់ក្រុមការពារ

[3] E46/1.1, ‘មរណភាពរបស់ នួន ជា“, ថ្ងៃទី៤ សីហា ២០១៩ (“លិខិតបញ្ជាក់មរណភាព”), ERN ០១៦២៣៦៥០ (ខ្មែរ), ០១៦២៣៦៥១ (អង់គ្លេស)

[4] F46/2.1.1, ‘លិខិតពីលោក នួន ជា ចាត់តាំងអ្នកតំណាងធ្វើសកម្មភាពជំនួសក្នុងព្រឹត្តិការណ៍ដែលគាត់ទទួលមរណភាពមុនពេលនីតិវិធីបណ្ដឹងសាទុក្ខបានបញ្ចប់ពេញលេញ“, ១២ កក្កដា ២០១៩ [ទម្រង់សម្រាប់សាធារណៈជន (មានលុបបិទព័ត៌មាន)] ។ ផងដែរមើល F46 ‘លិខិតពីលោក នួន ជា ចាត់តាំងអ្នកតំណាងធ្វើសកម្មភាពជំនួសក្នុងព្រឹត្តិការណ៍ដែលគាត់ទទួលមរណភាពមុនពេលនីតិវិធីបណ្ដឹងសាទុក្ខបានបញ្ចប់ពេញលេញ’, ១៨ កក្កដា ២០១៩។

[5] F46/1.1, លិខិតបញ្ជាក់មរណភាព។

ចំពោះផលប៉ះពាល់នៃមរណភាពរបស់លោក នួន ជា")។[6] ក្នុងសំណើនេះ ក្រុមមេធាវីការពារបាន ស្នើសុំដល់អង្គជំនុំជម្រះថា៖

(ក) បញ្ចប់នីតិវិធីបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០២ និងច្រានចោលអនុភាពអនុវត្តនៃសាលក្រមសាលាដំបូងពាក់ព័ន្ធនឹងលោកនួន ជា ពីព្រោះថាលោក នួន ជា នៅតែទទួលបានការសន្មតជាមុនថាគ្មានទោសក្រោយពេលលោកបានដាក់បណ្តឹងសាទុក្ខ ឬក៏

(ខ)អនុញ្ញាតអោយនីតិវិធីបណ្តឹងសាទុក្ខដំណើរការទៅមុខដើម្បីប្រយោជន៍យុត្តិធម៌ទោះបីជាលោក នួន ជា បានទទួលមរណភាពហើយក៏ដោយ ខណៈពេលដែលធានាថាលោក នួន ជា ត្រូវបានតំណាងដោយមេធាវីដែលជ្រើសតាំងតាមឆន្ទៈរបស់ខ្លួន។[7]

## IV. ស្ថានភាពបច្ចុប្បន្ននៃកិច្ចដំណើរការនីតិវិធី អ.វ.ត.ក ពាក់ព័ន្ធនឹង នួន ជា

៧. អង្គជំនុំជម្រះពុំទាន់បានផ្តល់សេចក្តីសម្រេចលើសំណើបន្ទាន់របស់ក្រុមមេធាវីការពារនៅឡើយនោះទេ ពាក់ព័ន្ធនឹងឥទ្ធិពលនៃមរណភាពរបស់លោក នួន ជា។ ដូចគ្នានេះដែរ អង្គជំនុំជម្រះពុំទាន់បានចេញនូវការសម្រេចមួយក្នុងការបញ្ចប់នីតិវិធីពាក់ព័ន្ធនឹងលោក នួន ជា នៅឡើយទេ។

៨. ទោះជាយ៉ាងក៏ដោយ អ្នកនាំពាក្យរបស់អ.វ.ត.ក និងប្រធានផ្នែកការងារសាធារណៈរបស់អ.វ.ត.ក ដែលប្រហែលជាការផ្តល់សារជំនួសរដ្ឋបាលនៅអ.វ.ត.ក តែងប្រកាសជាបន្តបន្ទាប់ម្តងហើយម្តង

[6] E46/2 'សំណើបន្ទាន់ពាក់ព័ន្ធនឹងឥទ្ធិពលនៃមរណភាពរបស់លោក នួន ជា មុនពេលទទួលបានសាលដីកា ទៅលើនីតិវិធីបណ្តឹងសាទុក', ០៦ សីហា ២០១៩ ("សំណើបន្ទាន់របស់ក្រុមការពារចំពោះឥទ្ធិពលនៃមរណភាពរបស់លោក នួន ជា")។

[7] E46/2, សំណើបន្ទាន់របស់ក្រុមការពារចំពោះឥទ្ធិពលនៃមរណភាពរបស់ នួន ជា

ទៀតថា នីតិវិធីពាក់ព័ន្ធនឹងលោក នួន ជា ត្រូវបានបញ្ចប់ ដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[8]

## V. ការបញ្ចប់ការងាររបស់ក្រុមមេធាវីការពារក្តី នួន ជា

៩. នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ ខណៈពេលដែលកំពុងធ្វើដំណើរទៅកាន់ពិធីបុណ្យសពរបស់លោក នួន ជា សមាជិកក្រុមមេធាវីការពារលោក នួន ជា ទាំងអស់ បានទទួលដំណឹងពីតំណាងរដ្ឋបាលរបស់ អ.វ.ត.ក ថា កិច្ចសន្យាការងារត្រូវបានលុបចោល។ សហមេធាវីការពារក្តីទាំងបីរូបបានទទួលលិខិតពីប្រធានអង្គភាពគាំពារការការពារក្តី មានខ្លឹមសារ (*ក្នុងចំណោមខ្លឹមសារទាំងស្រុង*) ថា៖

> *ជនដែលបានទទួលមរណភាពពុំមានសិទ្ធិទទួលបានការការពារសិទ្ធិក្រោមកិច្ចសន្យាផ្តល់សេវាកម្មច្បាប់នោះទេ។ គោលបំណងនៃកិច្ចសន្យាផ្តល់សេវាកម្មច្បាប់ត្រូវបានផុតរលត់ជាមួយនឹងមរណភាពរបស់លោក នួន ជា [...] ដោយពិចារណាថាលោក/លោកស្រីត្រូវការបំពេញទម្រង់នីតិវិធីរដ្ឋបាលដូចជាការបំពេញបែបបទចេញពីអ.វ.ត.ក អង្គភាពគាំពារការការពារក្តីនឹងរក្សាទុកកិច្ចសន្យាផ្តល់សេវាកម្មច្បាប់របស់លោក/លោកស្រី រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩។ ក្រោយថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៩*

---

[8] ឧទា. មើល វិទ្យុអាស៊ីសេរី, 'នួន ជា ស្លាប់ក្នុងជនមាយុ៩៣ឆ្នាំ បានបញ្ចប់ក្តីសង្ឃឹមរបស់ជនរងគ្រោះនៃរបបខ្មែរក្រហមក្នុងការបិទបញ្ចប់សំណុំរឿង", ០៥ សីហា ២០១៩ (ឯកសាភ្ជាប់ ១) ដកស្រង់ពាក្យសំដីរបស់អ្នកនាំពាក្យទាំងស្រុង "លោកនួន ជា បានទទួលមរណភាព ហេតុដូចនេះសំណុំរឿងរបស់គាត់ត្រូវបានបិទ"។ ជាង សុផេង "មនោគមវិជ្ជារបស់ខ្មែរក្រហមត្រូវបានបូជាហើយការប្តឹងសាទុក្ខប្រហែលជាអាចឈប់", វ៉ាស៊ិនតោនផុស, ០៩ សីហា ២០១៩ (ឯកសាភ្ជាប់ ២) ការពិណនារបស់អ្នកនាំពាក្យ "ក្រោមច្បាប់នៃរាជាណាចក្រកម្ពុជា ការចោទប្រកាន់តាមប្រព័ន្ធតុលាការត្រូវបានរលត់នៅពេលជនជាប់ចោទទទួលមរណភាព ហើយអង្គជំនុំជម្រះនឹងធ្វើការសម្រេចតាមការអនុវត្តនេះ។

*អង្គភាពគាំពារការការពារក្តីពុំមានកាតព្វកិច្ចក្នុងការបន្តការតបស្នងរាល់ការងារផ្សេងដែលធ្វើឡើងក្នុងនាមជំនួសអោយលោក [នួន ជា] នោះឡើយ។*[9]

១០. ដូចគ្នានេះដែរ ទីប្រឹក្សាក្នុងក្រុមទាំងប្រាំមួយរូបបានទទួលសារអេឡិចត្រូនិចនាថ្ងៃជាមួយគ្នាពីប្រធានផ្នែកធនធានមនុស្ស ផ្តល់ការណែនាំ ស្របគ្នា ថា៖

*នេះជាការជូនដំណឹងដល់លោក/លោកស្រីថា កិច្ចសន្យារបស់លោក/លោកស្រី ត្រូវកាត់បន្ថយ ហើយនិងត្រូវបានលុបចោលនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ តាមការណែនាំរបស់ប្រធានអង្គភាពគាំពារការការពារក្តី។ យើងធ្វើការជូនដំណឹងទុកជាមុននេះស្របតាមលក្ខខណ្ឌទូទៅនៃសេវាកម្ម ដើម្បី [អនុញ្ញាត] អោយអ្នកប្រឹក្សាយោបល់អាចបញ្ចប់ការងារដែលកំពុងកាន់កាប់ និងដើម្បីបញ្ចប់បែបបទ (ដាច់ដោយឡែក) ទាំងអស់។*[10]

១១. ទីប្រឹក្សាទាំងអស់ត្រូវបានផ្តល់ដំណឹងត្រឹម១០ថ្ងៃនៃថ្ងៃធ្វើការមុនការលុបចោលការងាររបស់ពួកគេ ក៏ប៉ុន្តែចំនួនថ្ងៃសម្រាកតាមច្បាប់ដែលពួកគេមានសិទ្ធិទទួលបានក្នុងអំឡុងពេលផ្តល់សេវានេះនៅសល់ច្រើន ពីព្រោះថាពួកគេបានពន្យាពេលការដាក់ស្នើសុំការសម្រាករបស់ពួកគេ ដោយមូលហេតុថា បរិមាណការងារពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខមានការលំបាកខ្លាំង ស្របពេលដែលសុខភាពរបស់លោក នួន ជា មានភាពទ្រុតទ្រោមខ្លាំង។ ពួកគេភាគច្រើនមានថ្ងៃឈប់សម្រាកដែលកិច្ចសន្យាពួកគេបានផ្តល់អោយ ច្រើនជាង១០ថ្ងៃទៅទៀត។ ទោះជាយ៉ាងណាក៏ដោយ ផ្នែកធនធានមនុស្ស ជូនដំណឹងតាមរយៈអង្គភាពគាំពារការការពារក្តីទៅកាន់ក្រុមមេធាវីការពារថា ទីប្រឹក្សាទាំងនោះនឹងពុំ

---

[9] 'លិខិតពីលោក Mario Hemmerling ប្រធានអង្គភាពគាំពារការការពារ ជូនទៅលោកមេធាវី សុន អរុណ លោកមេធាវី លីវ សុវណ្ណា និងលោកស្រីមេធាវី Doreen Chen ដែលជាសហមេធាវីរបស់លោក នួន ជា', ០៩ សីហា ២០១៩ (ភ្ជាប់ក្នុងឯកសារភ្ជាប់ ១)

[10] ឧទា. មើល 'សារអេឡិចត្រូនិចពីលោក លីម សុធា ប្រធានផ្នែកធនធានមនុស្ស ទៅលោកស្រី Xiaoyang Nie, អ្នកប្រឹក្សាជាន់ខ្ពស់របស់ក្រុមការពារក្តីនួន ជា', ០៩ សីហា ២០១៩ (ភ្ជាប់ក្នុងឯកសារភ្ជាប់ ២)

ទទួលបានការតបស្នងជាប្រាក់ចំពោះចំនួនថ្ងៃឈប់សម្រាកដែលនៅសេសសល់នៅពេលកិច្ចសន្យាពួកគេត្រូវបានបញ្ចប់ ហើយថាទីប្រឹក្សាគួរតែសុំឈប់សម្រាកភ្លាមៗដើម្បីអាចទទួលបាននូវសិទ្ធិដែលត្រូវបានផ្តល់អោយពួកគេ ឬសម្រេចថាបន្តធ្វើការដោយពុំទទួលបានការឈប់សម្រាកទាំងនោះ។

១២. ក្រុមមេធាវីការពារក្តី បានណែនាំឲ្យទីប្រឹក្សារបស់ខ្លួន ប្រើប្រាស់ថ្ងៃឈប់សម្រាកដែលពួកគេមាន ពីព្រោះថាជំហររបស់រដ្ឋបាលបែបនេះ នឹងបណ្តាលអោយខាតបង់ផលប្រយោជន៍របស់ពួកគេ។ ហេតុដូចនេះ បើក្រឡេកមើលតាមរូបភាពអនុវត្តជាក់ស្តែង ការលុបចោលការងាររបស់ទីប្រឹក្សារបស់ក្រុមមេធាវីការពារភាគច្រើន មានអានុភាពភ្លាមៗតែម្តង។

## ផ្នែកទី៣. ច្បាប់អនុវត្ត

១៣. វិធានផ្ទៃក្នុង វិធាន១០៤ *ស្ទួន*ចែងថា "រាល់វិធានដែលត្រូវអនុវត្តនៅអង្គជំនុំជម្រះសាលាដំបូង ត្រូវយកមកអនុវត្តចំពោះអង្គជំនុំជម្រះតុលាការកំពូល ក្នុងករណីសមស្រប ប្រសិនបើគ្មានបទប្បញ្ញត្តិដោយឡែកណាមួយនោះទេ។"

១៤. ក្រោមវិធានផ្ទៃក្នុង វិធាន៨៥ ប្រធានអង្គជំនុំជម្រះសាលាដំបូង ដោយមានការពិគ្រោះយោបល់ជាមួយចៅក្រមផ្សេងទៀត ជាអ្នក"ដឹកនាំកិច្ចដំណើរការនីតិវិធី" និង "ដើម្បីធានារ៉ាប់រងឲ្យមានសណ្តាប់ធ្នាប់ល្អក្នុងពេលសវនាការ"។ វិធានផ្ទៃក្នុង វិធាន ៨៥ (១) បានបញ្ជាក់យ៉ាងជាក់លាក់ថាប្រធានសាលាដំបូង "ត្រូវធានាដល់ការអនុវត្តសិទ្ធិការពារខ្លួនឲ្យប្រព្រឹត្តទៅបានដោយសេរី"។

## ផ្នែកទី៤. អំណះអំណាង

១៥. យ៉ាងហោចណាស់ ក្រុមមេធាវីការពារក្តីចាំបាច់បន្តការទំនាក់ទំនងជាមួយអង្គជំនុំជម្រះរហូតដល់មានការចេញសេចក្តីសម្រេចជាក់លាក់មួយ ដែលពាក់ព័ន្ធនឹងសំណើបន្ទាន់អំពីផលប៉ះពាល់នៃមរណភាពរបស់លោក នួន ជា។ ក៏ប៉ុន្តែ ការសម្រេចលុបចោលក្រុមការពារក្តីរបស់លោក នួន ជា ទាំងស្រុងនេះ នឹងរារាំងក្រុមមេធាវីការពារក្តីពុំអោយមានលទ្ធភាពធ្វើទំនាក់ទំនងខាងលើនេះបានឡើយ។ ការសម្រេចនៃរដ្ឋបាលរបស់អ.វ.ត.កនេះ រារាំងសមត្ថភាពរបស់មេធាវីការពារក្តីក្នុងការចូលរួមក្នុងសំណុំរឿងនេះប្រកបដោយប្រសិទ្ធភាព ដោយមូលហេតុថាការសម្រេចនេះ ដកហូតនូវធនធានមនុស្សរបស់ក្រុមមេធាវីការពារក្តី និងតម្លៃតបស្នង (ត្រឹមថ្ងៃទី៣១ ខែសីហា ២០១៩)។

**១៦.** ផលប៉ះពាល់អវិជ្ជមានដែលអាចស្តែងច្បាស់លើបញ្ហានេះ គឺថាតើក្រុមមេធាវីការពារក្តីនឹងអាចមានលទ្ធភាពទំនាក់ទំនងជាមួយអង្គជំនុំជម្រះតទៅទៀតបានដែរឬទេ ក្រោយពេលដែលមានការលុបចោលក្រុមការពារក្តីលោក នួន ជា មុនពេលអង្គជំនុំជម្រះចេញនូវសេចក្តីសម្រេចផ្សេងៗ ពាក់ព័ន្ធទៅនឹងសំណើផ្សេងៗរបស់ក្រុមមេធាវីការពារក្តី។ ហេតុដូចនេះ ជាឧទាហរណ៍ ប្រសិនបើអង្គជំនុំជម្រះមានសំណួរអំពីសំណើណាមួយរបស់ក្រុមមេធាវីការពារ ក្រុមមេធាវីការពារក្តីអាចនឹងពុំមានពេលវេលាសម្រាប់ឆ្លើយតបឲ្យអង្គជំនុំជម្រះបានវិញនោះទេ។ បន្ថែមពីនេះ នៅពេលដែលក្រុមមេធាវីការពារក្តីបានបំពេញនូវដំណើរការរដ្ឋបាលចាំបាច់ក្នុងការចាកចេញពីការងារចប់ភ្លាម ពួកគេនឹងបាត់បង់សិទ្ធិក្នុងការចូលក្នុងប្រព័ន្ធដើម្បីពិនិត្យមើលឯកសារសំណុំរឿងបានទៀតហើយ។ ជាលទ្ធផល នៅពេលដែលមានការសម្រេចពាក់ព័ន្ធទៅនឹងសំណួរដែលក្រុមមេធាវីការពារក្តីបានដាក់ចំពោះអង្គជំនុំជម្រះ ក្រុមមេធាវីការពារក្តី អាចត្រឹមទទួលដំណឹងបានយឺតយ៉ាវ នៅពេលដែលសេច

ក្ដីសម្រេចនោះបានបញ្ចេញនៅលើគេហទំព័រសាធារណៈ ហើយក្នុងករណីដែលសេចក្ដីសម្រេចនោះត្រូវបានចាត់ថ្នាក់ថាជាឯកសារសាធារណៈប៉ុណ្ណោះ។

១៧ បញ្ហាប្រឈមសំខាន់មួយទៀតគឺថាក្រុមមេធាវីការពារក្ដីនឹងបាត់បង់ទីប្រឹក្សារបស់ខ្លួន ព្រោះពួកគេនឹងត្រូវការស្វែងរកការងារផ្សេងជំនួស។ ប៉ុន្តែ ក្នុងករណីដែលអង្គជំនុំជម្រះអនុញ្ញាតឱ្យក្រុមមេធាវីការពារក្ដី ដំណើរការបន្តពាក់ព័ន្ធបណ្ដឹងសាទុក្ខរបស់លោក នួន ជា នោះវិធីសាស្ត្រការងារដែលមានប្រសិទ្ធិភាពបំផុតគឺការអនុញ្ញាតឱ្យទីប្រឹក្សា នៅតែបន្តជាផ្នែកមួយនៃក្រុមការពារក្ដីដោយមូលហេតុថាពួកគេមានការយល់ដឹងពីសំណុំរឿង និងទំហំការងារដែលមានស្រាប់។ ការបណ្ដេញហើយផ្ដល់ការងារឡើងវិញ ឬជ្រើសរើសសមាជិកក្រុមថ្មីនឹងបណ្ដាលអោយមាន ការចំណាយពេលវេលានៃដំណើរការរដ្ឋបាល ការខាតបង់ពេលវេលា ដោយសារតម្រូវការណែនាំហ្វឹកហាត់ឡើងវិញដល់សមាជិកក្រុមថ្មី និងការពន្យារពេលជាច្រើន ហើយវាអាចបណ្ដាលឲ្យមានការប៉ះពាល់លើថ្លៃចំណាយដែលកើតមាននៅផ្នែកជាច្រើននៃសាលាក្ដីនេះ ពីព្រោះថានីតិវិធីទាំងអស់នេះ អាចបង្ខំឲ្យមេធាវីការពារក្ដីស្នើសុំពន្យារពេលបន្ថែម ដើម្បីធ្វើការលើសារណាបណ្ដឹងសាទុក្ខរបស់លោក នួន ជា ប្រកបដោយខ្លឹមសារពេញលេញ។

១៨ ជាពិសេសទៀត ការបញ្ចប់ ឬការសម្រេចផ្សេងទៀតចំពោះកិច្ចដំណើរការនីតិវិធីទាក់ទងនឹងលោក នួន ជា ជាបញ្ហាច្បាប់ដែលអង្គជំនុំជម្រះតែមួយគត់មានសិទ្ធិសម្រេច។ លុះត្រាតែ ឬរហូតដល់ពេលដែលអង្គជំនុំជម្រះសម្រេចធ្វើដូច្នេះ មេធាវីការពារក្ដីមិនត្រឹមតែនៅមានសិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/ ០២ ក្នុងនាមជាមេធាវីដែលបានតែងតាំងដោយឆន្ទៈលោក នួន ជា ប៉ុណ្ណោះទេ គឺក្រុមមេធាវីការពារក្ដី ថែមទាំងត្រូវមានកាតព្វកិច្ចក្នុងការបំពេញការងារនេះ។ ដោយ

មូលហេតុនេះហើយ ក្រុមមេធាវីការពារក្តីមានសិទ្ធិជ្រើសរើស ទីប្រឹក្សាច្បាប់ ដើម្បីអនុញ្ញាតិអោយពួកគេអាចបំពេញតួនាទីរបស់ខ្លួនបានត្រឹមត្រូវ។ លើសពីនេះ មេធាវីការពារក្តីរបស់លោក នួន ជា ទាំងមូល មានសិទ្ធិទទួលបានសំណងសម្រាប់ការងារទាំងនេះរហូតដល់អង្គជំនុំជម្រះសម្រេចថាសំណុំរឿងនេះត្រូវបានបញ្ចប់។

១៩ ថាតើ ការការពារផលប្រយោជន៍របស់ លោក នួន ជា អាចត្រូវបានបន្ត ឬទេ ក្រោយមរណភាព គឺជាសំណួរដ៏ស្មុគស្មាញមួយក្នុងទិដ្ឋភាពច្បាប់។ វាមានការពាក់ព័ន្ធយ៉ាងខ្លាំងចំពោះសំណួរដែលក្រុមមេធាវីការពារក្តី បានដាក់ជូនដល់អង្គជំនុំជម្រះតាមរយៈ "សំណើបន្ទាន់របស់ក្រុមមេធាវីការពារក្តីចំពោះផលប៉ះពាល់នៃមរណភាពរបស់លោក នួន ជា"។ សំណួរទាំងនេះ គឺជាចំណោទបញ្ហាដ៏សំខាន់ដែលអាចមានផលវិបាកមិនត្រឹមតែចំពោះលោក នួន ជា ឬ ជនរងគ្រោះតែប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ប្រព័ន្ធច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចទៅនឹងប្រព័ន្ធយុត្តិធម៌អន្តរជាតិទូទៅ ដែលរហូតមកដល់ពេលនេះធ្លាប់ត្រឹមតែបានផ្តល់ការពិចារណាក្នុងកម្រិតមួយតែប៉ុណ្ណោះ ចំពោះផលប៉ះពាល់នៃមរណភាពរបស់ដើមបណ្តឹងសាទុក្ខក្នុងសំណុំរឿង ដែលមានភាពស្រដៀងនឹងសំណុំរឿង ០០២/០២។

២០. លើសពីនេះទៀត អង្គហេតុដែលរដ្ឋបាលរបស់អ.វ.ត.ក បានសម្រេចជាឯកតោភាគីក្នុងការបញ្ចប់ការងារក្រុមមេធាវីការពារក្តី នួន ជា ទាំងមូលនេះ ទោះបីជា ការពិតអង្គជំនុំជម្រះ ពុំទាន់បានចេញសេចក្តីសម្រេចមួយដើម្បីបញ្ចប់នីតិវិធី អាចស្តែងចេញថា រដ្ឋបាលនៅ អ.វ.ត.ក បានជ្រៀតជ្រែកអំណាចតុលាការរបស់អង្គជំនុំជម្រះ។ នេះជាការបំពានយ៉ាងជាក់ស្តែងទៅលើអំណាចដែលបាន

បែងចែកក្នុងរដ្ឋធម្មនុញ្ញ និងបំពានសិទ្ធិមូលដ្ឋានរបស់លោក នួន ជា ក្នុងការទទួលបានការការពារស្របច្បាប់រហូតដល់អង្គជំនុំជម្រះសន្មតថាសំណុំរឿងរបស់គាត់បានបិទបញ្ចប់។

២១ ជាចុងក្រោយ ក្រុមមេធាវីការពារក្តីមានបំណងគូសបញ្ជាក់ថាទង្វើរបស់រដ្ឋបាលនៅ អ.វ.ត.ក ក្នុងការដាក់ទីប្រឹក្សារបស់ខ្លួននៅក្នុងទីតាំងមួយដែលពួកគេមានអារម្មណ៍ថាត្រូវបានបង្ខំឱ្យលះបង់សិទ្ធិការងារមូលដ្ឋាន ដូចជា សិទ្ធិទទួលបានការឈប់សម្រាក ពុំគ្រាន់តែជាការរំលោភបំពានប៉ុណ្ណោះទេ តែវាជាការរំលោភបំពានដោយឥតលាក់លៀម ផ្ទុយនឹងគោលការណ៍ចំបងទាំងឡាយ ដែលអង្គការសហប្រជាជាតិផ្ទាល់មានគោលបំណងការពារ។

**ផ្នែកទី៥: សំណូមពរ**

២២ យោងតាមហេតុផលខាងលើ ក្រុមមេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះចេញដីកាបញ្ជាប់ជាបន្ទាន់ទៅរដ្ឋបាល អ.វ.ត.ក ដើម្បីតែងតាំងតំណែងសមាជិកទាំងអស់នៃក្រុមការពារក្តីរបស់លោក នួន ជា ឡើងវិញ រហូតដល់អង្គជំនុំជម្រះតុលាការកំពូលសម្រេចផ្សេងពីនេះ។

សហមេធាវីការពារក្តីលោក នួន ជា

សុន អរុណ លីវ សុវណ្ណា DOREEN CHEN